ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ : ០៥៨ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីកោះរ៉ុង នៃក្រុងកោះរ៉ុង ខេត្តព្រះសីហនុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងសេចក្តីសម្រេចលេខ០៤៥ ជនស.សសរ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីកោះរ៉ុង "ផែនទីបណ្តាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងបណ្តាញប្រភពទឹក នៅកោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ"
- យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីកោះរ៉ុង នៃក្រុងកោះរ៉ុង ខេត្តព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣៨ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុងត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុង ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីកោះរ៉ុងក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីកោះរ៉ុងមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីកោះរ៉ុង ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ និងអភិបាលនៃគណៈអភិបាលក្រុងកោះរ៉ុងនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីកោះរ៉ុង នៃក្រុងកោះរ៉ុង ខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣៨

## ប្លង់បណ្ដាញផ្លូវថ្នល់ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ និងបណ្ដាញប្រភពទឹកនៅកោះរ៉ុង

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ:...០៨៤ សសរ......... ចុះថ្ងៃ...សុក្រ.......៨កើត......ខែ..ពុស្ស........ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី..៣០............ខែ...ធ្នូ.............ឆ្នាំ២០២២






ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានរយៈបណ្ដោយទី១០២ អង្សា ដល់១០៨អង្សា និងរយៈទទឹងទី១២អង្សា ដល់១៥អង្សា។ ប្រទេសកម្ពុជាមានផ្ទៃដី១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ក្នុងនោះមានបណ្ដោយប្រមាណ៥៦០គីឡូម៉ែត្រ និងមានទទឹងប្រមាណ៤៤០គីឡូម៉ែត្រ ។ ប្រទេសកម្ពុជាមានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម មានប្រវែងប្រមាណ២១៦០គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែងប្រមាណ៤៤០គីឡូម៉ែត្រ ។



### ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចម្ងាយប្រមាណ២២៣គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានផ្ទៃដីសរុប ២៥២៨.៥៨គីឡូម៉ែត្រក្រឡា មានព្រំប្រទល់រដ្ឋបាលជាប់នឹងខេត្តកោះកុងនៅទិសពាយ័ព្យ ជាប់នឹងខេត្តកំពង់ស្ពឺនៅទិសឦសាន ជាប់នឹងខេត្តកំពតនៅទិសបូព៌និងអាគ្នេយ៍ និងជាប់នឹងសមុទ្រនៅទិសទក្សិណនិងនិរតី ។ ខេត្តនេះមានក្រុងចំនួនពីរគឺ ក្រុងព្រះសីហនុ និងក្រុងកោះរ៉ុង ស្រុកចំនួនបីគឺស្រុកព្រៃនប់ ស្រុកស្ទឹងហាវ និងស្រុកកំពង់សីលា ឃុំ/សង្កាត់ចំនួន២៩ និងភូមិចំនួន១១១២ ។ ខេត្តព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងទីផ្សារសកលលោក និងមជ្ឈមណ្ឌលឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ ។

### ក្រុងកោះរ៉ុង

ក្រុងកោះរ៉ុង ជាក្រុងប្រជុំកោះត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ០២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ មានផ្ទៃដី១១.៣២៣,៨៩ហិកតា មានសង្កាត់ចំនួនពីរគឺ សង្កាត់កោះរ៉ុង (ចំនួន៣ភូមិ) និងសង្កាត់កោះរ៉ុងសន្លឹម (ចំនួន២ភូមិ) ។ ក្រុងនេះមានចំងាយ២៥គីឡូម៉ែត្រ ពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងចម្ងាយ ១៧គីឡូម៉ែត្រ ពីស្រុកបុទុមសាគរ ខេត្តកោះកុង ។



### ការពិពណ៌នា

- ផែនទីនេះត្រូវបានផលិតឡើងនៅខែធ្នូ ឆ្នាំ២០២២ បង្ហាញពីបណ្ដាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទីតាំងរដ្ឋបាល និងបរិក្ខាសាធារណៈ ប្រភពទឹកនៅកោះរ៉ុង ចក្ខុវិស័យឆ្នាំ២០៣៨ ។
- ផែនទីនេះត្រូវបានរៀបចំឡើងដោយក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ដ.ន.ជ និងអគ្គលេខាធិការដ្ឋាន គ.អ.ឆ.ក សហការជាមួយក្រុមការងារសិក្សាហេដ្ឋារចនាសម្ព័ន្ធក្រុងកោះរ៉ុង ។
- ផែនទីនេះត្រូវបានរៀបចំឡើងដោយផ្អែកលើរូបថតពីលើអាកាសរបស់អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ថតនៅឆ្នាំ២០២២ និងការចុះប្រមូលទិន្នន័យដោយផ្ទាល់នៅកោះរ៉ុង ដោយប្រើប្រាស់ឧបករណ៍ GPS ដើម្បីស្រង់នូវនិយាមកានៃបណ្ដាញផ្លូវមានស្រាប់ បណ្ដាញអូរ ប្រឡាយ ផ្ទៃបឹង និងតំបន់សំខាន់ៗមួយចំនួនទៀត
- ប្រភេទផ្លូវត្រូវបានកំណត់បែងចែកជាមហាវិថី វិថី អនុវិថី និងផ្លូវធម្មជាតិនិងផ្លូវថ្មើរជើង ។

### មាត្រដ្ឋានផែនទី

មាត្រដ្ឋាន : 1:23,000

0 0.5 1 2 3 4 គម

១ សង់ទីម៉ែត្រ ស្មើនឹង ២៣០ម៉ែត្រ

សន្លឹកប្លង់: ០១ ប្រភេទក្រដាស A0

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ។
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុង ដែលមានក្រុមការងារមួយជាសេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុងកោះរ៉ុង ។

លេខ:...០៨៤...សសរ.........

**បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ..សុក្រ.....៨កើត..ខែ...ពុស្ស......ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី....៣០..........ខែ....ធ្នូ.......ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធាន**
**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

លេខ:...........................

**បានឃើញ និងឯកភាព**

គោរពជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធាន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃ...........................ខែ...........ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី....៣០...........ខែ....ធ្នូ.........ឆ្នាំ២០២២

**អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធាន**
**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ**

គួច ចំរើន

លេខ:...........................

**បានឃើញ និងឯកភាព**

គោរពជូន ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធាន គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ មេត្តាពិនិត្យ និងសម្រេច ។
ធ្វើនៅក្រុងកោះរ៉ុង ថ្ងៃ...........................ខែ...........ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី....៣០.......ខែ...ធ្នូ.........ឆ្នាំ២០២២

**អភិបាលនៃគណៈអភិបាលក្រុង និងជាប្រធាន**
**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកោះរ៉ុង**

ឡួន ម៉ិនផុល